# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការក្រសួងយុត្តិធម៌
លេខ ៩៧៨.ព្ររ.៣.២-៩៧

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ផ្ញើរជូន**

**លោកប្រធានតុលាការខេត្ត-ក្រុង**

**លោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីគោលការណ៍បង្ក្រាបអំពើល្មើសច្បាប់មួយចំនួន ។
**យោង:** វិធានការ ៨(ខ) របស់សម្ដេចនាយករដ្ឋមន្ត្រីទី ២ ។

ខ្ញុំសូមជម្រាបលោកថា សម្ដេចនាយករដ្ឋមន្ត្រីទី២ បានចាត់វិធានការ ៨(ខ) មុឹងមាត់ណាស់ ។ ដូច្នេះក្រសួងយុត្តិធម៌ ត្រូវតែអនុវត្តនូវគោលការណ៍នយោបាយច្បាប់មួយឱ្យបានសមស្របជាមួយវិធានការរបស់រាជរដ្ឋាភិបាល សម្រាប់បង្ក្រាបអំពើល្មើសច្បាប់មួយចំនួន ដែលបច្ចុប្បន្នកំពុងកើតមានយ៉ាងខ្លាំងខ្លានៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយទ្រទ្រង់ នឹងជួយជំរុញការអនុវត្តន៍វិធានការរបស់ប្រមុខរាជរដ្ឋាភិបាលនេះ ឱ្យទទួលបានលទ្ធផលល្អនិងមានប្រសិទ្ធិភាពខ្ពស់ជូនប្រជាពលរដ្ឋ និងជូនប្រទេសជាតិក្នុងការថែរក្សាសន្តិសុខសណ្ដាប់ធ្នាប់សង្គមដោយផ្អែកលើច្បាប់ ។

ចាប់ពីថ្ងៃនេះតទៅលោកព្រះរាជអាជ្ញានឹងលោកប្រធានតុលាការ ត្រូវយកចិត្តទុកដាក់សម្រេចចោទប្រកាន់ និងផ្ដន្ទាទោសជាអតិបរមានៃទោសដែលមានកំណត់ក្នុងច្បាប់ ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តបទល្មើស

១-បទល្មើសប្លន់ ដូចជាប្លន់ម៉ូតូ ប្លន់នៅតាមផ្លូវ ចូលប្លន់ក្នុងផ្ទះជាដើម ។

២-បទល្មើសចាប់ជំរិតមនុស្សយកលុយ

៣-បទល្មើសសម្លាប់មនុស្ស

៤-បទល្មើសដាក់ប៉ុស្ដិ៍ត្រួតពិនិត្យខុសច្បាប់ កុងត្រូលជជុះ

៥-បទល្មើសពង្រត់មនុស្សយកទៅធ្វើពេស្យាចារឬជួញដូរមនុស្ស

៦-បទល្មើសជួញដូរគ្រឿងញៀន ដែលមានចែងក្នុងច្បាប់ ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

ក្រៅពីនេះគប្បីយកចិត្តទុកដាក់សម្រេចចោទប្រកាន់ និងផ្ដន្ទាទោសឱ្យតឹងរឹងផងដែរចំពោះជនទាំងឡាយណាដែលកាន់កាប់ ថែរក្សា លាក់ទុក ដឹកជញ្ជូន ឬ ប្រើប្រាស់អាវុធខុសច្បាប់ បទល្មើសប្រភេទនេះជាបទល្មើសជាក់ស្ដែង ហេតុនេះត្រូវចោទប្រកាន់ជូនតុលាការជំនុំជម្រះភ្លាមៗ ឥតត្រូវជូនទៅចៅក្រមស៊ើបសួរធ្វើការស៊ើបអង្កេតអ្វីទៀតទេ ។

ទន្ទឹមនឹងបទល្មើសដូចបានរៀបរាប់ខាងលើ នៅមានបទល្មើសផ្សេងៗទៀតដែលជាកត្តាជំរុញឱ្យមានកើតឡើងនូវបទល្មើសលួច និង ប្លន់ គឺបទល្មើសក្លែងលិខិតសាធារណៈ និងប្រើប្រាស់លិខិតក្លែង ។

ចំពោះបទល្មើសកាន់កាប់ ថែរក្សា លាក់ទុក ដឹកជញ្ជូន ឬ ប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសក្លែងលិខិតសាធារណៈ និងប្រើប្រាស់លិខិតក្លែង មិនគប្បីតុលាការសម្រេចផ្ដន្ទាទោសអប្បបរមា ឬ ទាបជាងអប្បបរមានៃទោស

ដែលមានកំណត់ក្នុងច្បាប់ តុលាការត្រូវតែសម្រេចផ្តន្ទាទោសទាបបំផុតចាប់ពីត្រឹមពាក់កណ្តាលនៃទោសដែលមានកំណត់ក្នុងច្បាប់ទៅអតិបរមានៃទោស ។

ខ្ញុំសូមទាញអារម្មណ៍របស់លោកព្រះរាជអាជ្ញា និងលោកប្រធានតុលាការថា ចំពោះ អ្នកដាក់បុស្តិ៍ត្រួតពិនិត្យប្រព្រឹត្តទារលុយពីរថយន្ត និងពីអ្នកធ្វើដំណើរត្រូវបែងចែកជាពីរប្រភេទ ដើម្បីកំណត់បទល្មើសឱ្យបានច្បាស់លាស់គឺ

១-ចំពោះអ្នកដាក់បុស្តិ៍ត្រួតពិនិត្យ ដែលទទួលការចាត់តាំងត្រឹមត្រូវតាមច្បាប់ប៉ុន្តែប្រព្រឹត្តទារលុយពីអ្នកដំណើរខុសច្បាប់ ត្រូវសម្រេចចោទប្រកាន់និងផ្តន្ទាទោសពីបទស៊ីសំណូក តាមមាត្រា ៣៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ចំពោះអ្នកដាក់បុស្តិ៍ត្រួតពិនិត្យ នាំគ្នាធ្វើការត្រួតពិនិត្យចល័តខុសច្បាប់ទារលុយពីរថយន្ត និងអ្នកធ្វើដំណើរត្រូវសម្រេចចោទប្រកាន់ និងផ្តន្ទាទោសពីបទប្លន់ តាមមាត្រា ៣៤ ឬ បទក្រុមជនប្រដាប់អាវុធ តាមមាត្រា ៣៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

សូមលោកព្រះរាជអាជ្ញា និងលោកប្រធានតុលាការយកចិត្តទុកដាក់អនុវត្តតាមការណែនាំរបស់ក្រសួងនេះឱ្យមានរូបសិទ្ធិខ្ពស់បំផុត ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩៧

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

<u>ចម្លងជូន</u>

-តុលាការកំពូល

-មហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍និងមហាអយ្យការ

-ទីស្តីការគណៈរដ្ឋមន្ត្រី

- ដើម្បីជាប